COUNT US IN 2020

There's Power In Being Counted

ASIAN AMERICANS ADVANCING JUSTICE

COUNTUSIN2020.ORG

# របៀបកំណត់អត្តសញ្ញាណមន្ត្រីជំរឿន

*មានសំណួរមែនទេ? សូមហៅទូរស័ព្ទទៅកាន់ខ្សែទូរស័ព្ទទាន់ហេតុការណ៍ផ្នែកជំរឿនរបស់យើង តាមលេខ 844-2020-API សម្រាប់ជំនួយគាំទ្រជាភាសាអង់គ្លេស និងភាសាដទៃផ្សេងទៀត។ សូមចូលមើលគេហទំព័រ [www.CountUsIn2020.org/hotline](www.CountUsIn2020.org/hotline) សម្រាប់ព័ត៌មានបន្ថែម។*

## តើការិយាល័យជំរឿននឹងបញ្ជូននរណាម្នាក់មកផ្ទះរបស់ខ្ញុំឬ?

ការធ្វើជំរឿនបានចាប់ផ្ដើមនៅខែមករា ឆ្នាំ2020 នៅតំបន់ឆ្ងាយដាច់ស្រយាលនៃរដ្ឋអាឡាស្កា ហើយក្រុមគ្រួសារ សឹងទាំងអស់នឹងទទួលបានការអញ្ជើញរបស់ពួកគេឲ្យឆ្លើយតបនៅក្នុង **ខែមិនា ឆ្នាំ 2020**។
ការិយាល័យជំរឿននឹងផ្ញើការណែនាំ
និងការរំលឹកតាមសំបុត្រជូនលោកអ្នកដើម្បីបំពេញជំរឿនរហូតដល់ដំណាច់ខែមេសា។
លោកអ្នកអាចឆ្លើយតបតាមទូរស័ព្ទ តាមអនឡាញ ឬតាមរយៈទម្រង់បែបបទជាក្រដាស។
*ប្រសិនបើលោកអ្នកឆ្លើយតបនឹងជំរឿននៅខែមិនា ឬមេសា នោះមន្ត្រីជំរឿននឹងមិនមកដល់ផ្ទះរបស់លោកអ្នកដើម្បីយកការឆ្លើយតបដែលរំលងខកខានរបស់អ្នកឡើយ។ ចាប់ពីពាក់កណ្ដាលខែឧសភា មន្ត្រីជំរឿននឹងចុះទៅដល់ផ្ទះគ្រួសារណាដែលមិនទាន់បានឆ្លើយតបទៅនឹងជំរឿន។*

## តើមន្ត្រីជំរឿនគឺជានរណា?

មន្ត្រីជំរឿនគឺជាអ្នកដែលត្រូវបានជួលពីសហគមន៍ក្នុងមូលដ្ឋានរបស់លោកអ្នកដោយការិយាល័យជំរឿនដើម្បីចុះទៅដល់ផ្ទះរបស់លោកអ្នក និងប្រមូលចម្លើយជំរឿនសម្រាប់គ្រួសារទាំងអស់ដែលមិនទាន់បានបំពេញ។

## តើនៅពេលណាមន្ត្រីជំរឿននឹងចុះទៅដល់ផ្ទះរបស់លោកអ្នក?

សម្រាប់តំបន់ភាគច្រើន មន្ត្រីជំរឿននឹងចុះទៅដល់ផ្ទះចាប់ពីខែឧសភាដល់ចុងខែកក្កដា។
នៅក្នុងតំបន់ដែលមាននិស្សិតមហាវិទ្យាល័យរស់នៅក្រៅបរិវេណសាលា និងកន្លែងដែលមនុស្សរស់នៅជាក្រុមធំៗ (ឧទាហរណ៍ មជ្ឈមណ្ឌលចាស់ជរា) ដំណើរការនេះចាប់ផ្ដើមនៅដើមខែមេសា។

## នេះគឺជារបៀបដែលលោកអ្នកកំណត់អត្តសញ្ញាណមន្ត្រីជំរឿន៖

*ដំបូង ត្រូវសុំមើលស្លាកសម្គាល់ខ្លួនរបស់ពួកគេ។*
*គ្រប់បុគ្គលិកជំរឿនទាំងអស់មានពាក់ស្លាកសញ្ញាផ្លូវការរបស់រដ្ឋាភិបាលដែលរួមមាន ឈ្មោះ រូបថតពួកគេ ស្នាមមើលឃើញព្រិលៗនៃការិយាល័យជំរឿនសហរដ្ឋអាមេរិច និងកាលបរិច្ឆេទផុតកំណត់។*

*ឡូហ្គោការិយាល័យជំរឿនពី [www.census.gov](www.census.gov)*

- មន្ត្រីជំរឿនស្ពាយកាបូបផ្លូវការដែលមានឡូហ្គោការិយាល័យជំរឿន និងទូរស័ព្ទ iPhone។

- មន្ត្រីជំរឿននឹងផ្តល់ជូនលោកអ្នកនូវលិខិតជាភាសាអង់គ្លេសពីការិយាល័យជំរឿនដែលមានក្បាលលិខិត ផ្លូវការបញ្ជាក់ពីមូលហេតុដែលពួកគេមកដល់លំនៅឋានរបស់លោកអ្នក។
- មន្ត្រីជំរឿនធ្វើការងាររបស់ពួកគេនៅចន្លោះម៉ោង 9 ព្រឹកដល់ម៉ោង 9 ល្ងាច ម៉ោងក្នុងតំបន់។
- តាមការស្នើសុំ មន្ត្រីជំរឿននឹងផ្តល់ជូនលោកអ្នកនូវព័ត៌មានទំនាក់ទំនង និង/ឬលេខទូរស័ព្ទរបស់អ្នកមើលការខុសត្រូវផ្ទាល់របស់ពួកគេសម្រាប់មជ្ឈមណ្ឌលជំរឿនប្រចាំតំបន់របស់លោក ([https://2020census.gov/en/contact-us/rcc](https://2020census.gov/en/contact-us/rcc)) ដែលត្រួតពិនិត្យសកម្មភាពរបស់អ្នកតំណាងគ្រប់វិស័យ នៅក្នុងតំបន់របស់លោកអ្នក។
- ប្រសិនបើលោកអ្នកចង់បញ្ជាក់ដោយឯករាជ្យថា អ្នកដែលនៅមាត់ទ្វាររបស់លោកអ្នកជាបុគ្គលិកការិយាល័យជំរឿន លោកអ្នកអាចទាក់ទងមជ្ឈមណ្ឌលជំរឿនប្រចាំភូមិភាគសម្រាប់តំបន់អ្នកបាន។
- ***មន្ត្រីជំរឿននឹងមិនស្នើសុំចូលក្នុងផ្ទះរបស់លោកអ្នកទេ។***

## តើមន្ត្រីជំរឿននឹងសួរខ្ញុំពីអ្វីខ្លះ?

មន្ត្រីជំរឿននឹងសួរតែសំណួរដែលមាននៅក្នុងទម្រង់បែបបទជំរឿនប៉ុណ្ណោះ (លោកអ្នកត្រូវមានអាយុយ៉ាងតិច 15 ឆ្នាំដើម្បីឆ្លើយសំណួរ)៖ អាសយដ្ឋាន លេខទូរស័ព្ទ ចំនួនមនុស្សដែលរស់នៅក្នុងផ្ទះរបស់លោកអ្នក មិនថាតែលោកអ្នកជួល ឬជាម្ចាស់ផ្ទះ និងព័ត៌មានមូលដ្ឋានអំពីអ្នករស់នៅក្នុងផ្ទះម្នាក់ៗ (ឈ្មោះ អាយុ ថ្ងៃខែឆ្នាំកំណើត ភេទ ទំនាក់ទំនងជាមួយអ្នក ពូជសាសន៍ ជាតិពិន្ទុ)។ សូមចងចាំថា ត្រូវរាប់បញ្ចូលមនុស្សគ្រប់រូបដែលរស់នៅអាសយដ្ឋានរបស់លោកអ្នក -- ទារក កុមារតូចៗ សមាជិកគ្រួសារផ្សេងទៀត និងមិត្តរួមបន្ទប់។ ពេលខ្លះ យើងភ្លេចរាប់បញ្ចូល កុមារតូចៗ ប៉ុន្តែវាមានសារៈសំខាន់ណាស់ក្នុងការរាប់ពួកគេផងដែរ។ សូមមើលសន្លឹកព័ត៌មានរបស់យើងអំពីការរាប់គ្រួសារ និងកុមារតូចៗរបស់លោកអ្នកតាមគេហទំព័រ [www.CountUsIn2020.org/resources](http://www.CountUsIn2020.org/resources) សម្រាប់ព័ត៌មានបន្ថែម។

*មន្ត្រីជំរឿននឹងមិនសួរពីស្ថានភាពជាពលរដ្ឋ ប័ណ្ណបើកបរ លេខសន្តិសុខសង្គម ប័ណ្ណឥណទាន ធនាគារ ឬព័ត៌មានហិរញ្ញវត្ថុផ្សេងទៀត ប្រាក់ឬការបរិច្ចាក ឬ PIN កូដ ឬពាក្យសម្ងាត់របស់លោកអ្នកឡើយ។*
តើការិយាល័យជំរឿននឹងតាមដានជាមួយខ្ញុំយ៉ាងដូម្តេច ប្រសិនបើខ្ញុំមិនបំពេញជំរឿននៅខែឧសភា?

- ចាប់ផ្តើមនៅពាក់កណ្តាលខែឧសភា មន្ត្រីជំរឿននឹងមកដល់ផ្ទះរបស់លោកអ្នកដើម្បីប្រមូលចម្លើយរបស់លោកអ្នកសម្រាប់ជំរឿន។ លោកអ្នកអាចបំពេញជំរឿនរបស់លោកអ្នកជាមួយមន្ត្រីជំរឿននៅពេលពួកគេមកដល់មាត់ទ្វាររបស់លោកអ្នក។ ប្រសិនបើលោកអ្នកមិនធ្វើបែបនេះទេ លោកអ្នកនៅតែអាចបំពេញជំរឿនរបស់លោកអ្នកបានតាមរយៈការឆ្លើយតបដោយខ្លួនឯងតាមអនឡាញ ឬតាមរយៈទូរស័ព្ទរហូតដល់ខែកក្កដា។
- ប្រសិនបើគ្មាននរណាបើកទ្វារទេ ពួកគេនឹងទុកប័ណ្ណប្រៃសណីយ៍ "សេចក្តីជូនដំណឹងអំពីការមកជួបនៅផ្ទះ" ដែលមានលេខសម្គាល់គ្រួសារដែលលោកអ្នកអាចប្រើដើម្បីបំពេញជំរឿនតាមអនឡាញ ឬតាមទូរស័ព្ទ។
- ប្រសិនបើលោកអ្នកនៅតែមិនបំពេញ ពួកគេនឹងត្រឡប់មកវិញ ហើយទុកប័ណ្ណប្រៃសណីយ៍តាមដានមួយសន្លឹកនៅមួយសប្តាហ៍ក្រោយ។
- មន្ត្រីជំរឿននឹងបន្តមកដល់ផ្ទះ ឬទូរស័ព្ទមករហូតដល់ចំនួនប្រាំមួយដង។
- បន្ទាប់ពីការព្យាយាមលើកទីបី មន្ត្រីជំរឿនអាចសាកសួរ ដែលគួរឱ្យទុកចិត្តបានដែល នៅម្តុំនោះដើម្បីទទួលបានព័ត៌មាន ដូចជា អ្នកជិតខាង អ្នករត់សំបុត្រ ។ល។ បន្ទាប់មក មន្ត្រីជំរឿននឹងបំពេញការឆ្លើយតបដោយផ្អែកលើព័ត៌មាននោះ។
- **ជំនួយផ្នែកភាសា៖** នៅពេលមន្ត្រីជំរឿនជួបប្រទះនឹងឧបសគ្គផ្នែកភាសានៅមាត់ទ្វារ ពួកគេនឹងអាចបង្ហាញប័ណ្ណ សម្គាល់ភាសាដែលសំដែងចេញជាលក្ខណៈពិសេសនូវសេចក្តីថ្លែងការណ៍ខ្លីជាភាសាមិនមែនអង់គ្លេសចំនួន 59 ភាសា។ មន្ត្រីជំរឿនប្រើប្រាស់ប័ណ្ណសម្គាល់ភាសា ដើម្បីជួយកំណត់អត្តសញ្ញាណភាសាដែលត្រូវបាននិយាយដោយក្រុមគ្រួសារ ហេតុនេះនរណាម្នាក់ដែលនិយាយភាសានោះអាចតាមដានបន្តជាមួយក្រុមគ្រួសារនោះបាន។

*អ្នកអាចស្វែងរកព័ត៌មានបន្ថែមទៀតអំពីជំរឿននៅ [www.CountUsIn2020.org/resources](http://www.CountUsIn2020.org/resources)*។

## របៀបកំណត់អត្តសញ្ញាណមន្ត្រីជំរឿន

លោកអ្នកអាចបំពេញជំរឿន៖

- ☑ **តាមអនឡាញ**
- ☑ **តាមទូរស័ព្ទ**
- ☑ **តាមទម្រង់បែបបទជាក្រដាស**

**ចាប់ពីពាក់កណ្ដាលខែឧសភា ឆ្នាំ2020 មន្ត្រីជំរឿននឹងចុះទៅដល់ផ្ទះគ្រួសារណាដែលមិនទាន់បានបំពេញជំរឿន។**



មន្ត្រីជំរឿនអាចត្រូវបានកំណត់អត្តសញ្ញាណ ដោយការិយាល័យជំរឿនផ្លូវការរបស់ពួកគេ៖

**ប័ណ្ណសម្គាល់ខ្លួន**
**កាបូបឬកុំព្យូទ័រយួរដៃ**
**សំបុត្រ**

*លោកអ្នកក៏អាចបញ្ជាក់ថាពួកគេគឺជានិយោជិតរបស់ការិយាល័យជំរឿនបានផងដែរដោយទាក់ទងមជ្ឈមណ្ឌលជំរឿនប្រចាំភូមិភាគសម្រាប់តំបន់អ្នក។*

មន្ត្រីជំរឿននឹងមិនស្នើសុំចូលក្នុងផ្ទះរបស់លោកអ្នកទេ

មន្ត្រីជំរឿននឹងសួរតែសំណួរដែលមាននៅក្នុងទម្រង់បែបបទជំរឿនប៉ុណ្ណោះ

សូមចងចាំថា ត្រូវរាប់បញ្ចូលមនុស្សគ្រប់រូបដែលរស់នៅក្នុងអាសយដ្ឋានរបស់លោកអ្នក **ដោយរួមបញ្ចូលទាំង ទារក កុមារតូចៗ សមាជិកគ្រួសារផ្សេងទៀត និងមិត្តរួមបន្ទប់**

មន្ត្រីជំរឿននឹងមិនស្នើសុំ៖

- ☒ **ប័ណ្ណបើកបរ**
- ☒ **លេខសន្តិសុខសង្គម**
- ☒ **ប័ណ្ណឥណទាន ធនាគារ ឬព័ត៌មានហិរញ្ញវត្ថុផ្សេងទៀត**
- ☒ **ប្រាក់ឬការបរិច្ចាក**
- ☒ PIN **កូដ ឬពាក្យសម្ងាត់**